ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារជូនពរ

## សូមគោរពជូន

## សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៧២ ឈានចូល ៧៣ ឆ្នាំ

**សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមប្រកបដោយសេចក្តីសោមនស្សរីករាយ នៃពិធីចម្រើនជន្មាយុគម្រប់ ៧២ ឈានចូល ៧៣ ឆ្នាំ របស់សម្តេចដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៧នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមភរិយាខ្ញុំ និងខ្លួនខ្ញុំផ្ទាល់ សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរគ្រប់យ៉ាង ជូនចំពោះសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** និង **លោកជំទាវ** សូមសម្តេចទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីរួមចំណែកកសាងសមិទ្ធផលថ្មីៗថែមទៀតជូនជាតិមាតុភូមិនិងប្រជាពលរដ្ឋ។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរព និងស្វាមីភក្តិយ៉ាងជ្រាលជ្រៅបំផុតចំពោះគុណូបការៈដ៏ធំធេងពុំអាចកាត់ថ្លៃបានរបស់ **សម្តេច** ដែលបានបូជាអស់កម្លាំងកាយចិត្តប្រាជ្ញាស្មារតីនិងរាល់បទពិសោធន៍ក្នុងការដឹកនាំស្ថាប័នព្រឹទ្ធសភាឱ្យក្លាយជាអង្គនីតិប្បញ្ញត្តិមួយប្រកបដោយសក្តានុពលភាព សំដៅពង្រឹងនីតិរដ្ឋឱ្យកាន់តែរឹងមាំ ឈានទៅសម្រេចបានគោលដៅអភិវឌ្ឍប្រទេសជាតិឱ្យសម្បូររុងរឿង។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមភរិយាខ្ញុំ និងខ្លួនខ្ញុំផ្ទាល់ សូមលើកហត្ថបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះអង្គតាមជួយបីបាច់ថែរក្សាប្រោះព្រំសព្ទសាធុការពរជ័យ ជូនចំពោះ **សម្តេច** ប្រធានព្រឹទ្ធសភា និង **លោកជំទាវ** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រីជាទីស្រឡាញ់ សូមសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** និង **លោកជំទាវ** មេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**